# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL

លេខ និងឈ្មោះសំណុំរឿង : ១៦៧/០៩–ហ្វូវ ម៉ាក
កាលបរិច្ឆេទនៃសេចក្តីបង្គាប់ : ថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០៩

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា៣១៣នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក : ម៉ារ សំបូរណា

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត : ទួន ស៊ីផាន់

ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ : ប៉ែន ប៊ុនឈា

## ភាគីវិវាទ

១- ភាគីនិយោជក

ឈ្មោះ : ក្រុមហ៊ុន ហ្វូវ ម៉ាក អ៊ិនធើប្រាយ (ខេមបូឌា) ខូ អិលធីឌី

អាសយដ្ឋាន : ផ្លូវជាតិលេខ ៤ ភូមិដំណាក់រំពិល ស្រុកអង្គស្នួល ខេត្តកណ្តាល

ទូរស័ព្ទ : ០៩២ ២២៨ ១៥៨ ទូរសារលេខ :

តំណាងភាគីនិយោជក :

១- លោក ឆិន ជឹង ប្រធានគ្រប់គ្រង

២- លោក រ៉ុង លាភ ប្រធានរដ្ឋបាល

២- ភាគីកម្មករនិយោជិត

ឈ្មោះ : - សហព័ន្ធសហជីពយុវជនខ្មែរ

- សហជីពយុវជនខ្មែរ នៃក្រុមហ៊ុន ហ្វូវ ម៉ាក

អាសយដ្ឋាន : ផ្លូវជាតិលេខ ៤ ភូមិដំណាក់រំពិល ស្រុកអង្គស្នួល ខេត្តកណ្តាល

ទូរស័ព្ទ : ០១២ ៩០៧ ៩០២ ទូរសារ : គ្មាន

តំណាងកម្មករនិយោជិត : អវត្តមាន



មជ្ឈមណ្ឌលភ្នំពេញ អគារ A បន្ទប់លេខ ៣៣១ វិថីសុធារស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ។ ទូរស័ព្ទ/ទូរសារ : ០២៣ ២២០ ៧៩៣
Phnom Penh Center (A), Room 331, Sothearos Blvd, Sangkat Tonle Basak, Khan Chamkar Morn, Phnom Penh • Tel/Fax: 023 220 793
Email: secretariat@arbitrationcouncil.org • Website: www.arbitrationcouncil.org

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- នៅពេលក្រុមហ៊ុនគ្មានការងារឱ្យកម្មករធ្វើការម្តងម្កាល សុំគិតប្រាក់ឈ្នួលគោលពេញ ។ ក្រុមហ៊ុនគ្មានលទ្ធភាព ព្រោះក្រុមហ៊ុនអាចផ្តល់ជូនកម្មករតែ ៣០ ភាគរយ (សាមសិបភាគរយ) នៃប្រាក់ឈ្នួលគោល ។

២- សុំឱ្យក្រុមហ៊ុនកុំដូរថ្ងៃខែកាតរបស់កម្មករ ក្រុមហ៊ុនសុំអនុវត្តតាមគោលការណ៍ចាស់ គឺកម្មករពេញសិទ្ធិទើបរៀបគិតអតីតភាពការងារពីពេលនោះមក ។

៣- នៅពេលកម្មករសុំច្បាប់មានធុរៈឈឺ មានលិខិតបញ្ជាក់ពីគ្រូពេទ្យត្រឹមត្រូវ សុំឱ្យក្រុមហ៊ុនរក្សាប្រាក់ឈ្នួល ប្រាក់រង្វាន់ធ្វើការទៀងទាត់ ។ ក្រុមហ៊ុនមិនឯកភាព ។

៤- សុំឱ្យក្រុមហ៊ុនរៀបចំឱ្យមានស្បែកជើងសំរាប់កម្មករពាក់ចូលក្នុងអគារពាណិជ្ជកម្ម ។

៥- សុំឱ្យក្រុមហ៊ុនបើកលុយបាយមួយអាទិត្យម្តងជូនកម្មករ ។

៦- សុំឱ្យក្រុមហ៊ុនបន្ថែមម៉ាស៊ីនវាយបុង ហើយកុំប្រញ៉ាប់ដកបុង ។

៧- សុំឱ្យក្រុមហ៊ុនប្រក់ដំបូលរោងសម្រាប់កម្មករជ្រកនៅមុខរោងចក្រ ។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ(ខ) (មាត្រា ៣០៩ ដល់៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល លេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាស លេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ១៥០ កប/ប្រក ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០០៩ (អាណត្តិទី៧) ។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី ២ (ក) នៃច្បាប់ស្តីពីការងារ ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការមិនសះជា លេខ ៩៩២/០៩ កប/កណ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០០៩ ។

## សវនាការ និង សង្ខេបនីតិវិធី

ទីកន្លែងសវនាការ : ក្រុមប្រឹក្សាអាជ្ញាកណ្តាល មជ្ឈមណ្ឌលភ្នំពេញ អគារ A វិថីសុធារស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ។

កាលបរិច្ឆេទសវនាការ : ថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០០៩ (វេលាម៉ោង ០៨:៣០ នាទី ព្រឹក)

ក្រុមប្រឹក្សាអាជ្ញាកណ្តាល THE ARBITRATION COUNCIL

**បញ្ហានៃនីតិវិធី :**

នៅថ្ងៃទី២៦ ខែតុលា ឆ្នាំ២០០៩ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកណ្តាល បានទទួលបណ្តឹងចំនួន ១២ ចំណុច របស់សហព័ន្ធសហជីពយុវជនខ្មែរ ដែលទាមទារឱ្យក្រុមហ៊ុនធ្វើការកែលំអរលក្ខខណ្ឌការងារនៅក្នុងក្រុមហ៊ុនឱ្យបានល្អប្រសើរ។ បន្ទាប់ពីបានទទួលបណ្តឹងនេះមក មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកណ្តាល បានចាត់តាំងមន្ត្រីជំនាញធ្វើការដោះស្រាយវិវាទការងារនេះជាបន្តបន្ទាប់ និងធ្វើការផ្សះផ្សាជាលើកចុងក្រោយ នៅថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០០៩ ដោយបានទទួលលទ្ធផលសះជាចំនួន ០៥ ចំណុច លើការទាមទារចំនួន ១២ ចំណុច។ ចំណុចមិនសះជាចំនួន ០៧ ចំណុចនេះ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០០៩។

បន្ទាប់ពីបានទទួលសំណុំរឿងរួចមក លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល បានធ្វើការកោះអញ្ជើញភាគីក្រុមហ៊ុន និងភាគីកម្មករនិយោជិតមកសវនាការ និងធ្វើការផ្សះផ្សាលើករណីមិនសះជាចំនួន ០៧ ចំណុចនេះ ថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០០៩ (វេលាម៉ោង ០៨:៣០ នាទី ព្រឹក)។ ដល់កាលកំណត់នៃសវនាការ ភាគីនិយោជកមានវត្តមានតាមការអញ្ជើញរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ដើម្បីចូលរួមធ្វើការដោះស្រាយវិវាទការងាររួមនេះ ប៉ុន្តែ ភាគីកម្មករនិយោជិត ដែលជាដើមបណ្តឹងនៃវិវាទនេះ ពុំបានមានវត្តមានតាមការអញ្ជើញរបស់លេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាលទេ រហូតដល់វេលាម៉ោង ៨:៤៥ នាទី ទើបតំណាងសហព័ន្ធសហជីពយុវជនខ្មែរទូរស័ព្ទមកមន្ត្រីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល ប្រាប់ថា មិនអាចចូលរួមបានទេ ស្នើសុំលើកពេល ដោយលើកហេតុផលថា សហជីពមូលដ្ឋាន និងកម្មករនិយោជិត ពុំបានដឹងថា មានសវនាការនៅក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅថ្ងៃនេះ ហើយម៉្យាងទៀត មានបុគ្គលិកម្នាក់ដែលត្រូវចូលរួមរមនៅក្នុងសវនាការកំពុងមានជំងឺ។ ដូចនេះពួកគាត់សំណូមពរធ្វើការពន្យាពេលសវនការ ឬសូមឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលចាត់វិធានការទៅតាមនីតិវិធីច្បាប់ចុះ។ ហេតុនេះហើយ ក្រុមប្រឹក្សាអាជ្ញាកណ្តាល ធ្វើការពិចារណា ដូចខាងក្រោម:

ឧបសម្ព័ន្ធ

សាក្សី និង អ្នកជំនាញក្រៅពីភាគី : គ្មាន

ឯកសារ ឧបសម្ព័ន្ធ ដែលក្រុមប្រឹក្សាអាជ្ញាកណ្តាលយកមកពិចារណាមាន

ក- ឯកសារបានទទួលពីភាគីនិយោជក : គ្មាន

ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត : គ្មាន

គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន ហួរ ម៉ាក លេខ [illegible]២/០៩ កប/វកល ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩។

២- កំណត់ហេតុដោះស្រាយវិវាទការងាររួម នៅក្រុមហ៊ុន ហ្វូរ ម៉ាក ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០០៩។

**ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល**

១- លិខិតអញ្ជើញភាគីនិយោជកជ្រើសរើសក្រុមអាជ្ញាកណ្តាលលេខ ៨៥៨ កប/អក/វក/លកអ. ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០០៩។

២- កំណត់ហេតុស្តីពីការចាប់ឆ្នោតជ្រើសរើសអាជ្ញាកណ្តាលពីបញ្ជីឈ្មោះអាជ្ញាកណ្តាលស្នើដោយសមាគមនិយោជក ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០០៩។

៣- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការលេខ ៨៦២ កប/អក/វក/លកអ. ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០០៩។

៤- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការលេខ ៨៦៣ កប/អក/វក/លកអ. ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០០៩។

**អង្គហេតុ**

ក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនអាចរកឃើញអង្គហេតុទាក់ទងនឹងការទាមទារនេះទេ ដោយហេតុថា ភាគីកម្មករនិយោជិត ដែលជាដើមបណ្តឹងនៅក្នុងសំណុំរឿងនេះ បានអវត្តមាននៅក្នុងថ្ងៃសវនាការ ដូចនេះ ពួកគាត់ពុំបានបង្ហាញពីខ្លឹមសារនៃការទាមទាររបស់ខ្លួន និងលើកបញ្ជាក់ពីមូលហេតុរបស់ខ្លួនក្នុងការទាមទារនោះឡើយ។

**ហេតុផលនៃសេចក្តីសម្រេច :**

ភាគីកម្មករនិយោជិត ដែលជាដើមបណ្តឹងនៅក្នុងសំណុំរឿងនេះ មិនបានទៅចូលរួមក្នុងសវនាការទេ។ នៅព្រឹកថ្ងៃសវនាការ តំណាងសហព័ន្ធសហជីពដែលពាក់ព័ន្ធនៅក្នុងសំណុំរឿងនេះ បានទូរស័ព្ទទៅប្រាប់លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលថា ភាគីកម្មករនិយោជិតមិនអាចមកចូលរួមសវនាការទេ ដោយសារសហជីពមិនបានដឹង ហើយមានកម្មករនិយោជិតម្នាក់ ដែលជាតំណាងកម្មករនិយោជិត ដែលត្រូវចូលរួមអមនៅក្នុងសវនាការឈឺ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា មូលហេតុដែលភាគីកម្មករនិយោជិតលើកឡើងថា ខ្លួនមិនដឹងថ្ងៃសវនាការនោះ មិនត្រឹមត្រូវ និងមិនសមហេតុផលទេ ពីព្រោះលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលបានជូនដំណឹងទៅភាគីទាំងសងខាង ដោយត្រឹមត្រូវ ដូចមានបញ្ជាក់ជូន ដូចខាងក្រោម:

តាមប្រការ ២១ នៃប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ចែងថា " *ក្នុងករណីភាគីណាមួយបានទទួលការអញ្ជើញត្រឹមត្រូវហើយ តែបែរជាខកខានមិនបានមកបង្ហាញខ្លួននៅចំពោះមុខក្រុមអាជ្ញាកណ្តាល ដោយគ្មានបង្ហាញមូលហេតុត្រឹមត្រូវ ក្រុមអាជ្ញាកណ្តាលអាចបើកសវនាការរបស់ខ្លួនក្នុងពេលដែលភាគីនោះអវត្តមាន ឬអាចបញ្ចប់នីតិវិធីការអាជ្ញាកណ្តាលដោយចេញសេចក្តីសម្រេចបាន* "។

THE ARBITRATION COUNCIL

បន្ថែមពីនេះទៀត វិធាន ៤.៧ នៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងឧបសម្ព័ន្ធនៃប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ចែងថា " *ប្រសិនបើភាគីណាមួយមិនបានបង្ហាញខ្លួន ឬមិនមានអ្នកតំណាងក្នុងដំណើរការអាជ្ញាកណ្តាល ក្រុមអាជ្ញាកណ្តាលអាចបន្តដំណើរការរបស់ខ្លួន ក្នុងអវត្តមានរបស់ភាគីនោះ ឬអាចបញ្ចប់ដំណើរការអាជ្ញាកណ្តាល ដោយចេញជាសេចក្តីបង្គាប់។ ក្នុងករណីណាមួយ ក្រុមអាជ្ញាកណ្តាលត្រូវតែបំពេញតាមល័ក្ខខ័ណ្ឌថា ភាគីវិវាទបានទទួលការជូនដំណឹងយ៉ាងត្រឹមត្រូវអំពីកាលបរិច្ឆេទ ពេលវេលា និងទីកន្លែងនៃដំណើរអាជ្ញាកណ្តាល មុនពេលធ្វើសេចក្តីសម្រេចរបស់ខ្លួន* "។

ផ្អែកលើប្រការ ២១ និងវិធាន ៤.៧ ខាងលើនេះ និងនៅក្នុងសេចក្តីបង្គាប់លេខ ១៦/០៧-ឡូទូសតី. លេខ ១៣៨/០៨-ម៉ាកលីន. លេខ ១៥១/០៨-វិល សិន. លេខ ០៩/០៩-នីមបឹស ថិចថាយ៏ និងលេខ ៤៥/០៩-វ៉ាយ ថិច ប្អាមេន ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា មានលក្ខខណ្ឌបី ដែលត្រូវបំពេញមុនពេល ដែលក្រុមប្រឹក្សាអាជ្ញាកណ្តាល អាចបញ្ចប់ដំណើរការអាជ្ញាកណ្តាល ដោយចេញជាសេចក្តីបង្គាប់បាន។ លក្ខខណ្ឌទី១ គឺភាគីត្រូវបានជូនដំណឹងដោយត្រឹមត្រូវ។ លក្ខខណ្ឌទី២ គឺភាគីដើមបណ្តឹងមិនបានបង្ហាញខ្លួននៅក្នុងសវនាការ និងលក្ខខណ្ឌទី៣ គឺភាគីដើមបណ្តឹង មិនបានផ្តល់មូលហេតុសម្រាប់ការមិនបង្ហាញខ្លួន។

ក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាល នឹងពិចារណាថា តើលក្ខខណ្ឌទាំងបីត្រូវបានបំពេញដែរ ឬទេ?

**លក្ខខណ្ឌទី ១ : ភាគីត្រូវបានជូនដំណឹងដោយត្រឹមត្រូវ**

ដូចដែលបានបញ្ជាក់ក្នុងវិធាន ៤.៧ ខាងលើ ក្រុមអាជ្ញាកណ្តាលអាចបន្តដំណើរការរបស់ខ្លួនក្នុងអវត្តមានរបស់ភាគីនោះ ឬអាចបញ្ចប់ដំណើរការអាជ្ញាកណ្តាល ដោយចេញជាសេចក្តីបង្គាប់ ប្រសិនបើភាគីណាមួយមិនបានបង្ហាញខ្លួន ឬមិនមានអ្នកតំណាងក្នុងដំណើរការអាជ្ញាកណ្តាល ក្នុងករណីដែលភាគីវិវាទត្រូវបានជូនដំណឹងយ៉ាងត្រឹមត្រូវ អំពីកាលបរិច្ឆេទ ពេលវេលា និងទីកន្លែង នៃដំណើរអាជ្ញាកណ្តាល។

ក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានរកឃើញថា លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលបានធ្វើលិខិតអញ្ជើញជាផ្លូវការ ចូលរួមសវនាការ ទៅភាគីទាំងពីរ តាមរយៈលិខិតអញ្ជើញលេខ ៨៦២ កប/អក/វក/លករ. ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០០៩ ហើយនីតិវិធីនេះ ត្រូវបានធ្វើជាប្រចាំដែរ។ ទន្ទឹមនេះ លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលបានបញ្ជាក់បន្ថែម តាមរយៈទូរស័ព្ទ នៅថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០០៩ ដល់ភាគីវិវាទ អំពីកាលបរិច្ឆេទ ពេលវេលា និងទីកន្លែង នៃថ្ងៃសវនាការផងដែរ។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា លក្ខខណ្ឌទី១នេះ លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល បានបំពេញរួចរាល់ហើយ។

THE ARBITRATION COUNCIL

លក្ខខណ្ឌទី ២ : ភាគីដើមបណ្តឹងមិនបានបង្ហាញខ្លួននៅក្នុងសវនាការ

ប្រការ ១៩ នៃប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល លេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ ២០០៤ ចែងថា *"ភាគីវិវាទអាចមកបង្ហាញខ្លួននៅចំពោះមុខក្រុមអាជ្ញាកណ្តាលដោយផ្ទាល់ខ្លួន ឬដោយមានអ្នកអម ឬតំណាងដោយមេធាវី ដែលជាសមាជិកនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ឬដោយបុគ្គលផ្សេងទៀត ដែលបានទទួលការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីភាគីនោះ ។"*

បន្ថែមពីនេះទៀត ប្រការ២០ នៃប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ក៏បានចែងថា *"ក្នុងអំឡុងពេលនៃដំណើរការរបស់ក្រុមអាជ្ញាកណ្តាល ..... ភាគីទាំងនេះ ត្រូវតែចូលរួមគ្រប់កិច្ចប្រជុំទាំងឡាយ ដែលក្រុមអាជ្ញាកណ្តាលបានអញ្ជើញឱ្យចូលរួម ។"*

នៅក្នុងករណីនេះ ភាគីនិយោជក បានចូលរួមតាមការអញ្ជើញរបស់លេខាធិការដ្ឋានត្រឹមត្រូវ ប៉ុន្តែ ភាគីកម្មករនិយោជិតជាភាគីដើមបណ្តឹងមិនបានចូលរួមសវនាការទេ ហើយក៏មិនបានចាត់ឱ្យមានអ្នកតំណាង ដូចជាខាងសហព័ន្ធសហជីព សហជីព មេធាវី ឬថ្នាក់គ្រប់គ្រង ដែលអាចទទួលអំណាចតំណាង ដើម្បីតំណាងពួកគេនៅក្នុងសវនាការនោះទេ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ដល់វេលាដែលចាប់ផ្តើមសវនាការ នាម៉ោង ៨:៣០ នាទី ភាគីកម្មករនិយោជិត មិនបានជូនព័តិមានមកក្រុមប្រឹក្សាអាជ្ញាកណ្តាលទេ រហូតដល់វេលាម៉ោង ៨:៤៥ នាទី ទើបភាគីសហព័ន្ធសហជីពយុវជនខ្មែរ បានបញ្ជាក់មកលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាអាជ្ញាកណ្តាលតាមរយៈទូរស័ព្ទថា ខ្លួនពុំអាចមកចូលរួមនៅក្នុងសវនាការ តាមកាលបរិច្ឆេទដែលបានកំណត់នោះទេ។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា លក្ខខណ្ឌទី២ ក៏ត្រូវបានបំពេញដែរ គឺភាគីកម្មករនិយោជិតដែលជាដើមបណ្តឹង មិនបានចូលរួមក្នុងសវនាការ ។

លក្ខខណ្ឌទី ៣ : ភាគីមិនបានផ្តល់មូលហេតុត្រឹមត្រូវសម្រាប់ការមិនបង្ហាញខ្លួន

ដូចដែលបានបញ្ជាក់ក្នុងប្រការ ២១ នៃប្រកាសខាងលើ ក្រុមអាជ្ញាកណ្តាលអាចបន្តដំណើរការរបស់ខ្លួនក្នុងពេលដែលភាគីនោះអវត្តមាន ឬអាចបញ្ចប់ដំណើរការអាជ្ញាកណ្តាលដោយចេញជាសេចក្តីបង្គាប់ ក្នុងករណីភាគីណាមួយបានទទួលការអញ្ជើញត្រឹមត្រូវហើយ តែបែរជាខកខានមិនបានមកបង្ហាញខ្លួន នៅចំពោះមុខក្រុមអាជ្ញាកណ្តាល ដោយគ្មានបង្ហាញមូលហេតុត្រឹមត្រូវ។ ក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា នៅវេលាថ្ងៃសវនាការ ភាគីកម្មករនិយោជិតជាភាគីដើមបណ្តឹង បានអវត្តមាន ដោយពុំមានធ្វើការជូនដំណឹងមុនមកលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាលទេ រហូតដល់ពេលថ្ងៃសវនាការ ទើបសហព័ន្ធសហជីពយុវជន[illegible] ថា សហជីពមូលដ្ឋាន និងកម្មករនិយោជិតមិនអាចមកចូលរួមបានទេ ពីព្រោះពុំបានដឹងថា [illegible]សវនាការនៅក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅថ្ងៃនេះទេ ហើយម្យ៉ាងទៀត មានកម្មករនិយោជិតម្នាក់ដែល[illegible]កម្មករនិយោជិត

ដែលត្រូវចូលរួមអម នៅក្នុងសវនាការកំពុងមានជំងឺ ដូចនេះ ពួកគាត់សំណូមពរធ្វើការពន្យាសវនការនេះ ឬ សូមឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាល ចាត់វិធានការទៅតាមនីតិវិធីច្បាប់ចុះ។ ក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា មូលហេតុដែលភាគីសហជីពលើកឡើងនោះ ពុំមានលក្ខណៈសមហេតុផល និងច្បាស់លាស់ដែលធ្វើឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលអាចទទួលយកបាននោះទេ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា លេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល បានជូនដំណឹងទៅភាគីវិវាទ នៅថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០០៩ អំពីកាលបរិច្ឆេទ នៃសវនាការដែលត្រូវធ្វើនៅថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០០៩។ ហេតុនេះ ភាគីកម្មករនិយោជិតមាន រយៈពេល ០៧ថ្ងៃ ដើម្បីត្រៀមរៀបចំឯកសារ និងព័ត៌មានពាក់ព័ន្ធ ដើម្បីយកមកបញ្ជាក់បង្ហាញ នៅក្រុមប្រឹក្សាអាជ្ញាកណ្តាល ហើយរយៈពេលនេះ គឺជារយៈពេលដ៏សមរម្យមួយ ដែលភាគីអាចមានលទ្ធភាពធ្វើបាន ក្នុងករណីដែលភាគីកម្មករនិយោជិត មានធុរៈសំខាន់ ឬបន្ទាន់ណាមួយ ដែលពុំអាចចូលរួមនៅថ្ងៃសវនាការបានទេ ភាគីកម្មករនិយោជិត គួរតែធ្វើការជូនដំណឹងជាលាយលក្ខអក្សរជាមុន មកក្រុមប្រឹក្សាអាជ្ញាកណ្តាលតាមរយៈលេខាធិការដ្ឋាន ក្នុងការសុំពន្យាពេលនេះជៀសវាងអវត្តមានដោយពុំបានជូនដំណឹងបែបនេះ។ ទន្ទឹមនេះដែរ ក្រុមប្រឹក្សារាជ្ញាកណ្តាលយល់ឃើញថា នៅពេលដែលភាគីកម្មករនិយោជិត ដែលជាដើមបណ្តឹងនៃវិវាទមិនទៅចូលរួមក្នុងសវនាការ ដោយមិនបានបញ្ជាក់មូលហេតុឱ្យបានត្រឹមត្រូវ និងឱ្យបានសមហេតុផលសម្រាប់លើកពេលសវនាការទេ គឺអាចចាត់ទុកថា ដើមបណ្តឹងបានបោះបង់បណ្តឹងរបស់ខ្លួនវិញហើយ។

ហេតុនេះហើយ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា លក្ខខណ្ឌទីពាក់ត្រូវបានបំពេញដែរ គឺភាគីកម្មករនិយោជិតមិនមានមូលហេតុត្រឹមត្រូវ និងសមហេតុផលសម្រាប់អវត្តមានរបស់ខ្លួនក្នុងសវនាការ។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច បិទសំណុំរឿង លេខ ១៦៧/០៩- ហួរ ម៉ាក នេះ ដោយភាគីកម្មករនិយោជិតបានអវត្តមាននៅពេលសវនាការ។

ដោយសំអាងលើអង្គហេតុ ភស្តុតាង និងអង្គច្បាប់ ដូចបានការពន្យល់ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចដូចតទៅនេះ:

## សម្រេច និង បង្គាប់

- បិទសំណុំរឿងលេខ ១៦៧/០៩- ហួរ ម៉ាក។

ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក :

ឈ្មោះ : **ម៉ារ សំបូរណា**

ហត្ថលេខា: --------------------------------

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត :

ឈ្មោះ : **ទួន ស៊ីផាន់**

ហត្ថលេខា: --------------------------------

ប្រធានក្រុមអាជ្ញាកណ្តាល :

ឈ្មោះ : **ម៉ែន ម៊ុនឈា**

ហត្ថលេខា: --------------------------------

THE ARBITRATION COUNCIL